# ស្ថានទូតអូស្ត្រាលី

# រាជធានីភ្នំពេញ

## សេចក្តីប្រកាសពត៌មាន

## រដ្ឋាភិបាលអូស្ត្រាលីគាំទ្រមជ្ឈមណ្ឌលពត៌មានស្ត្រី ដើម្បីកាត់បន្ថយអំពើហឹង្សាចំពោះស្ត្រី

ប្រទេសអូស្ត្រាលីកំពុងអនុវត្តការងារឆ្ពោះទៅរកការបញ្ចប់អំពើហឹង្សាចំពោះស្ត្រី និងកុមារី ។ ការប្រយុទ្ធប្រឆាំងនេះ ចាំបាច់ត្រូវមានសកម្មភាពជាលក្ខណៈសកលយ៉ាងមោះមុតដើម្បីធានាថា អំពើហឹង្សានឹងមិនបន្តបង្អាក់ការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ សេដ្ឋកិច្ច និងសង្គម ក្នុងសហគមន៍របស់ពួកគេឡើយ ។

ដើម្បីអបអរសាទរទិវាសិទ្ធិនារីអន្តរជាតិឆ្នាំ ២០១២ ស្ថានទូតអូស្ត្រាលីប្រចាំរាជធានីភ្នំពេញ មានក្តីសោមនស្សរីករាយសូមប្រកាសថា រដ្ឋាភិបាលអូស្ត្រាលី បានផ្តល់ថវិកាចំនួន ៧៩.០០០ ដុល្លាអូស្ត្រាលី ដែលស្ថិតនៅក្រោមផែនការថវិកាឆ្នាំ ២០១១-២០១២ របស់រាជរដ្ឋាភិបាលអូស្ត្រាលីសម្រាប់គាំទ្រផ្នែកសិទ្ធិមនុស្ស ដល់មណ្ឌលពត៌មានស្ត្រី ។ មណ្ឌលពត៌មានស្ត្រីនឹងប្រើប្រាស់ថវិកានេះ ដើម្បីរៀបចំបង្កើតយុទ្ធនាការពត៌មានក្នុងគោលបំណងបញ្ចប់នូវអំពើហឹង្សាលើផ្លូវភេទ និងការរំលោភសេពសន្ថវៈ និងលើកកំពស់ការយល់ដឹងផ្នែកច្បាប់ ។

អំពើហឹង្សាចំពោះផ្លូវភេទ គឺជាអំពើរមួយដែលមានលក្ខណៈទូទៅជាងគេនៃអំពើហឹង្សាផ្នែកយេនឌ័រ ដែលកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ករណីភាគច្រើនបានកើតមានឡើងដោយពុំមានការរាយការណ៍ ដោយហេតុថាជារឿយៗ ប្រជាពលរដ្ឋមួយចំនួននៅក្នុងសហគមន៍មូលដ្ឋាន ចាត់ទុកបទល្មើសទាំងនេះថាជាបញ្ហាឯកជន ។ ជនរងគ្រោះទទួលបានការគាំទ្រតិចតួចតែប៉ុណ្ណោះ ហើយផ្ទុយទៅវិញ ជារឿយៗត្រូវបានទទួលការរិះគន់ពីសំណាក់ក្រុមគ្រួសារ និងអ្នកជិតខាង ។ ស្ត្រីគ្រប់វ័យដោយរួមទាំងកុមារីផងដែរ សុទ្ធតែជាជនរងគ្រោះនៃសោកនាដកម្មនេះ ។

ថវិកានេះ នឹងផ្តល់ការគាំទ្របន្ថែមចំពោះកម្មវិធីដែលមានស្រាប់របស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារ ។ គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា

ដែលទទួលបានថវិកាគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី (CCJAP) កំពុងសហការការងារយ៉ាងជិតស្និតជាមួយគណៈកម្មាធិការភូមិឃុំមានសុវត្ថិភាព ដើម្បីជួយកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារនៅតាមសហគមន៍របស់ពួកគេ បន្ទាប់ពីការគាំទ្រដើម្បីលើកកំពស់នូវការតែងតាំង និងការជំរុញលើកកំពស់ស្ត្រីក្នុងជួរនគរបាលជាតិកម្ពុជា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ។

តាមរយៈការរួមបញ្ចូលការងារនេះជាមួយនឹងស្ថាប័នយុត្តិធម៌ រដ្ឋាភិបាលអូស្ត្រាលីបានផ្តល់ការគាំទ្រផងដែរដល់អង្គការមិនមែនរាជរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយសារអំពើហឹង្សាក្នុងគ្រួសារ ដែលក្នុងនោះរួមមាន៖ អង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា ដែលបានជួយស្ត្រីដើម្បីទទួលបានយុត្តិធម៌តាមរយៈតុលាការ អង្គការហាហ្គាដែលបានអនុវត្តការងារជាមួយជនរងគ្រោះដែលបានប៉ះទង្គិចខាងស្មារតីយ៉ាងធ្ងន់ធ្ងរដោយសារអំពើហឹង្សាចំពោះផ្លូវភេទ និងអំពើហឹង្សាក្នុងគ្រួសារ និងអង្គការយុវតារាដែលបានរៀបចំដាក់អ្នកស្ម័គ្រចិត្តនៅតាមភូមិ ដើម្បីជួយផ្លាស់ប្តូរអាកប្បកិរិយា របស់បុរស ស្ត្រី កុមារា និងកុមារី ពាក់ព័ន្ធនឹងអំពើហឹង្សាចំពោះស្ត្រីនៅតាមគេហដ្ឋាន និងក្នុងសហគមន៍ ។

ផ្នែកមួយនៃថវិកាឆ្នាំ ២០១១-១២ រដ្ឋាភិបាលអូស្ត្រាលីបានប្រកាសថា នឹងធ្វើការផ្តល់ថវិកាចំនួន ៩៦,៤ លានដុល្លាអូស្ត្រាលី សម្រាប់រយៈពេល ៤ ឆ្នាំសម្រាប់គំនិតផ្តួចផ្តើមដើម្បីបញ្ចប់អំពើហឹង្សាចំពោះស្ត្រី និងគាំទ្រស្ត្រីដែលបានរងគ្រោះដោយសារអំពើហឹង្សានៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងទ្វីបអាព្រិច មជ្ឈិមបូព៌ា អាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូង អាស៊ីកណ្តាល និងប៉ាស៊ីភិច ។ រដ្ឋាភិបាលអូស្ត្រាលី ទទួលស្គាល់ថា អំពើហឹង្សាចំពោះស្ត្រី ក៏នៅតែជាបញ្ហានៅប្រទេសរបស់ខ្លួនផងដែរ ហើយក្នុងឆ្នាំ ២០១១ កន្លងទៅនេះ រដ្ឋាភិបាលអូស្ត្រាលី បានប្រកាសអំពីផែនការថ្នាក់ជាតិមួយ ដើម្បីកាត់បន្ថយអំពើហឹង្សាចំពោះស្ត្រី និងកុមារ ។ នាថ្ងៃទី ៨ ខែមិនា ឆ្នាំ ២០១២ ការិយាល័យសម្រាប់ស្ត្រីរបស់រដ្ឋាភិបាលអូស្ត្រាលី បានបើកធ្វើសេចក្តីប្រកាសផែនការសកម្មភាពជាតិរបស់រដ្ឋាភិបាលអូស្ត្រាលី ស្តីពីសេចក្តីសម្រេច ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ ។

ទំនាក់ទំនងសាកសួរព័ត៌មាន៖ Dave Gordge, អនុប្រធានបេសកកម្ម,
០២៣ ២១៣ ៤៧០

**ស្ថានទូតអូស្ត្រាលី រាជធានីភ្នំពេញ**

**ថ្ងៃទី ៨ ខែមិនា ឆ្នាំ ២០១២**